USAID
ជំនួយពីពលរដ្ឋអាមេរិក

WORLD EDUCATION

# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC)

ឆ្នាំទី ១ លេខ ២ ខែ មិថុនា ឆ្នាំ ២០១០

## ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

### លទ្ធផលទទួលបាន

- សិស្សានុសិស្សប្រមាណជាង ៤៧០០ នាក់ទទួលបានសេវាពីប្រព័ន្ធកុមារជួយកុមារ

- កម្មវិធីវិទ្យុស្តីពីបំណិនជីវិតត្រូវបានបង្កើត និងចាក់ផ្សាយបានពីរហើយ

- ការងារដែលសម្រេចបាន រឺកំពុងដំណើរការលើផ្នែកអនាម័យទឹកស្អាត និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដោយគម្រោង IBEC ធ្វើបាន ៧១០ ហើយ

### ដៃគូរបស់ IBEC

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ។ គម្រោងនេះត្រូវបានប្រតិបត្តិដោយអង្គការអប់រំពិភពលោក (World Education) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា (MoEYS) ។

*ដៃគូក្នុងស្រុកមានអង្គការ :*
WC RD, BSDA. NEP និង EDA

*ដៃគូអន្តរជាតិមានអង្គការ :*
Equal Access និង វិទ្យាស្ថានស្រាវជ្រាវសហរដ្ឋអាមេរិក (AIR)

## ពិធីបើកជាផ្លូវការនៃគម្រោង IBEC ដែលប្រារព្ធធ្វើឡើងដោយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) ដែលទទួលបានថវិកាជំនួយពីទី ភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានបង្ហាញអោយឃើញនូវការទទួលបានជោគជ័យនាត្រីមាសទី២ ដោយមានសេចក្តីប្រកាសចាប់ផ្តើមដំណើរការជាផ្លូវការរបស់គម្រោង IBEC នៅថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១០ ដែលបង្ហាញអោយឃើញពីដំណើរការរីកចម្រើនទៅមុខ ក្នុងនោះមានសកម្មភាពសមាសភាគនៃគម្រោងសំខាន់ៗចំនួន៤ :
(១) ការកសាងសមត្ថភាពរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងការស្វែងរកការគាំទ្រសម្រាប់និរន្តរភាព (២) សមធម៌ក្នុងការទទួលបានការអប់រំច្រើនជាងមុន (៣) កែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍ និង (៤) បង្កើនបរិបទពាក់ព័ន្ធលើការអប់រំ ។

សេចក្តីប្រកាសចាប់ផ្តើមដំណើរការជាផ្លូវការរបស់គម្រោង IBEC បានប្រារព្ធធ្វើឡើងនៅថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១០ នៅឯគេហដ្ឋានរបស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ដែលឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកជាអ្នករៀបចំព្រឹត្តិការណ៍នេះ ។ ការប្រារព្ធពិធីនេះ មានអ្នកចូលរួមសំខាន់ៗជាច្រើន រួមមានមន្ត្រីជាន់ខ្ពស់មកពីក្រសួងអប់រំ យុវជន និង កីឡា ដូចជា ឯក ឧត្តម អ៊ឹម សិទ្ធី និង ឯកឧត្តម ណាត ប៊ុនរឿន ជាដើម ។ ហើយក៏មានតំណាងមកពីភ្នាក់ងារអភិវឌ្ឍន៍សំខាន់ៗនៅក្នុងវិស័យអប់រំនេះផងដែរ ដូចជា អង្គការ UNICEF អង្គការសង្គ្រោះកុមារ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ។ លើសពីនេះទៅទៀតក៏មានការចូលរួមពីប្រធានមន្ទីរអប់រំខេត្តផ្សេងៗទៀតផងដែរ ។ ព្រឹត្តិការណ៍នេះ ជាឱកាសបង្ហាញអោយឃើញថា USAID មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍លើវិស័យអប់រំ ហើយក៏បង្ហាញអោយឃើញផងដែរនូវសកម្មភាព ដែលបានដំណើរការ និងចែកផ្សាយព័ត៌មានអំពីសកម្មភាពទាំងនេះតាមរយៈ សារព័ត៌មាន ដោយមានក្រុមអ្នកសារព័ត៌មានចូលរួមក្នុងព្រឹត្តិការណ៍នេះផងដែរ ។



*Carol A. Rodley ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ទទួលស្វាគមន៍ ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡានាពេលប្រកាសបើកគម្រោង IBEC ជាផ្លូវការ ។*

*ការិយាល័យអង្គការអប់រំពិភពលោក : ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ (៨៥៥-២៣) ២១ ៦៨ ៥៤ ទូរសារលេខ ២១៨ ៣៦៩* E-mail: worldedcam@worlded.org.kh

## សមាសភាគ ១ ៖ ការកសាងសមត្ថភាពរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងការស្វែងរកការគាំទ្រសម្រាប់និរន្តរភាព



ក្នុងអំឡុងត្រីមាសទី២នេះ សមាសភាគទីមួយ បានផ្តោតការយកចិត្តទុកដាក់ចំពោះការវាយតម្លៃទៅលើការចាត់ចែងការងាររបស់ភ្នាក់ងារជាដៃគូដោយប្រើប្រាស់ឧបករណ៍ដែលត្រូវបានបង្កើតឡើងកាលពីត្រីមាសមុន ការប្រើប្រាស់ឧបករណ៍វាយតម្លៃរបស់ IBEC មានដូចជាកម្រងសំណួរបុគ្គលិក និងកម្រងសំណួរក្រុមប្រឹក្សាភិបាល ។ ដៃគូរបស់ IBEC អាចវាយតម្លៃបាននៅចំណុចមួយចំនួន ដូចជាផ្នែកអភិបាលកិច្ច ការគ្រប់គ្រងកម្មវិធី ធនធានមនុស្ស ហិរញ្ញវត្ថុ និងការគ្រប់គ្រងការងារផ្សេងៗ ។ ការឱ្យពិន្ទុក្នុងការវាយតម្លៃនេះគឺជាការវាស់វែងទៅលើសមត្ថភាពរបស់ដៃគូដែលទទួលបានប្រសិទ្ធិភាពលើការងារកម្រិតណានោះ និងការគ្រប់គ្រងរបស់គម្រោងដែលត្រូវការទទួលថវិកាជំនួយដោយផ្ទាល់ពីម្ចាស់អំណោយធំៗ មានដូចជាទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិជាដើម ។ ក្រោយពីពិនិត្យឡើងវិញនៅលទ្ធផលដែលបានមកពីការវាយតម្លៃនោះ ដៃគូធ្វើការកំណត់ការពិតជាក់ស្តែងនូវអ្វីដែលទទួលបានសម្រាប់ ខែ កញ្ញា ទៅមុខទៀត ( រហូតដល់ខែ ធ្នូ ឆ្នាំ ២០១០ ) ។ កម្រិតគុណភាពនេះនិងក្លាយជាមូលដ្ឋានសម្រាប់ការវាយតម្លៃចុងក្រោយ ដែលនឹងធ្វើនៅបំណាច់ឆ្នាំទី១ ។ ជាការសំខាន់ណាស់ទាំងដំណើរការវាយតម្លៃ និងកម្រិតគុណភាពដែលកំណត់បានដោយដៃគូការងារនេះបង្ហាញឱ្យឃើញថា ការកសាងសមត្ថភាពរបស់ IBEC ។ សម្អាងលើដៃគូរបស់ខ្លួនផ្ទាល់ដើម្បីកែលម្អ និងអភិវឌ្ឍរៀបចំអង្គការរបស់ខ្លួន ។ ក្រុមកសាងសមត្ថភាពរបស់ IBEC បានធ្វើការយ៉ាងជិតស្និទ្ធជាមួយបុគ្គលិករបស់ដៃគូ ដើម្បីកំណត់ថាតើសកម្មភាពណាខ្លះ ដែលត្រូវជួយឧបត្ថម្ភ និងបណ្តុះបណ្តាល ដែលចាំបាច់នឹងត្រូវទទួលបានត្រឹមកម្រិតណា ។

## ការអប់រំបញ្ជ្រាបតាមរយៈកម្មវិធីវិទ្យុ

យុទ្ធសាស្ត្រសំខាន់របស់ IBEC ដើម្បីការគាំទ្រដល់សកម្មភាពនេះ គឺការអប់រំបញ្ជ្រាបតាមកម្មវិធីវិទ្យុ ។ ក្នុងត្រីមាសនេះ អង្គការ Equal Access ដែលជាដៃគូរបស់ IBEC បង្កើតបានកម្មវិធីវិទ្យុពីរហើយ ដោយមានអមជាមួយនូវការធ្វើលំហាត់ដែលជាផ្នែកមួយរបស់កម្មវិធី ***យើងអាចធ្វើបាន*** គឺជាផ្នែកមួយនៃកម្មវិធីវិទ្យុលើផ្នែកបំណិនជីវិត ។ ជាបន្តបន្ទាប់មានកម្រងផែនការ និងសកម្មភាពព្រាង Script ។ ឈុតទីមួយត្រូវបានចាក់ផ្សាយរួចមកហើយនាថ្ងៃទី ១៧ ខែ មីនា នៅតាមស្ថានីយ៍វិទ្យុពីរនៅខេត្តកំពង់ចាម ។ ចំពោះឈុតទី ២ ត្រូវបានចាក់ផ្សាយរួចមកហើយផងដែរ នៅថ្ងៃទី ២៥ ខែមីនាកន្លងទៅនេះ ។ ឈុតនីមួយៗត្រូវបានចាក់ផ្សាយពីរដងនៅតាមស្ថានីយ៍ទាំងពីរ ហើយនៅពេលចាក់ផ្សាយម្តងៗ គឺមានការចាប់អារម្មណ៍ជាខ្លាំងដែលវេទិកានេះ ត្រូវបានគេអាចដឹងឮនៅក្នុងម៉ោងសិក្សា ហើយក្រោយម៉ោងសិក្សាសិស្សានុសិស្សក៏អាចដឹងឮតៗគ្នាបានដែរតាមរយៈសិស្សនិងគ្រូរបស់គេ។

ចំពោះកម្មវិធី ***យើងអាចធ្វើបាន*** មានពិធីករជាយុវវ័យពីរនាក់សម្រាប់ឆ្លងឆ្លើយចំពោះយុវសិស្សដែលជាអ្នកស្តាប់ ។ ការចូលរួមជាភ្ញៀវនៅក្នុង Studio រាល់ឈុតនីមួយៗគឺការដើរតួសម្រាប់ប្រធានបទនៃឈុតនោះ អ្នកដែលជាប់រវល់ជាមួយពិធីករក្នុងការសារសងនេះគឺជាអ្នកតំណាងឱ្យការជជែកក្រៅម៉ោងសិក្សាដោយមិត្តភ័ក្ររបស់គេ ។ ការដើរតួសុទ្ធតែទាក់ទងទៅនឹងរឿងរបស់គេ ដែលភ្ជាប់ទៅនឹងប្រធានបទនៃឈុតនីមួយៗ ហើយបន្ទាប់មករាល់ការបកប្រែឈុតនីមួយៗ ធ្វើយ៉ាងណាឱ្យបានជាឈុតឆាកខ្លីៗ ។ នៅពេលស្តាប់រឿង អ្នកស្តាប់ត្រូវបង្ហាញពីសារដែលបានលើកឡើងពីតួអង្គសំខាន់ៗ ទស្សនិកជនក៏ដូចជាតួអង្គសម្តែងគឺចាំបាច់ត្រូវប្រឈមដោះស្រាយបញ្ហារបស់គេ ។ ការជជែកដោយពិធីករ និងតួសម្តែងធ្វើឡើងដោយមានជំនួយពីសាច់រឿង និងផ្តោតទៅលើសារសំខាន់ៗ ។ ឈុតពីរដំបូងនៃកម្មវិធី ***យើងអាចធ្វើបាន*** បានបង្ហាញនូវប្រធានបទពីសីលធម៌ក្នុង និងក្រៅសាលា តើ ធ្វើយ៉ាងណាដើម្បីឱ្យក្លាយជាសិស្សល្អ ( ទាក់ទងទៅនឹងការសម្រេចបានជោគជ័យ នាចុងឆ្នាំសិក្សា និងធ្វើយ៉ាងណាឱ្យមានអនាគតល្អ ) ។

ការផ្សារភ្ជាប់កម្មវិធីវិទ្យុនេះ អង្គការ Equal Access បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការអប់រំពិភពលោក និងអង្គការ ខេប ដែលបង្កើតបានជាក្រុមសិស្សអ្នកស្តាប់ចំនួន ២០នាក់ និងក្រុមសន្ទនានៅក្នុងសាលាទូទាំងខេត្តកំពង់ចាម ។ រាល់ពេលចាក់ ផ្សាយកម្មវិធី ***យើងអាចធ្វើបាន*** សមាជិកក្រុមអ្នកស្តាប់បានជួបជុំគ្នាស្តាប់នូវវេទិកាដែលចាក់ផ្សាយ និងពិភាក្សាប្រធានបទនៃឈុតនីមួយៗក្នុងចំណោមក្រុមរបស់គេ ជាសរុបក្នុងក្រុមអ្នកស្តាប់ និងសន្ទនាមានចំនួន ២១ នាក់បានជួបជុំគ្នា ហើយការប្រជុំពិភាក្សាគ្នាត្រូវបាន ធ្វើឡើងផងដែរក្នុងត្រីមាសនេះ ជាសរុបមានយុវវ័យចូលរួមចំនួន ៤១២ នាក់ ។





## សមាសភាគ ២ : សមធម៌ក្នុងការទទួលបានការអប់រំច្រើនជាងមុន

សមាសភាគនេះទទួលខុសត្រូវចំពោះការងារពីរ គឺ ការគ្រប់គ្រងកម្មវិធីអាហារូបករណ៍ និងមូលនិធិសម្រាប់សាលាជម្រើសដែលរៀបចំកម្មវិធីដោយអ្នកដែលពាក់ព័ន្ធ។

### *ការផ្តល់អាហារូបករណ៍*

បុគ្គលិក IBEC នៅត្រីមាសទី២នេះបានបន្តផ្តល់ជំនួយដល់សាលាជាគោលដៅទាំងឡាយ ដើម្បីគាំទ្រដល់ដំណើរការផ្តល់អាហារូបករណ៍ ។ ការចែកចាយនេះត្រូវបានធ្វើឡើងចំពោះសិស្ស ចំនួនប្រហែល៣ពាន់នាក់នៅកម្រិត បឋម សិក្សានិង ៦៣៥នាក់នៅកម្រិតមធ្យមសិក្សា។ IBEC ក៏កំពុងតែគាំទ្រដល់សិស្សចំនួន១២០នាក់នៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ថ្នាក់ខេត្តផងដែរ។ សិស្សទាំងនេះបានឧបត្ថម្ភទឹកប្រាក់ជាលើកទី២ ៧៥ដុល្លាសម្រាប់រយៈពេល៣ខែ ប្រាក់ចំនួន៩ពាន់ដុល្លាទៅឱ្យ PTTC និមួយៗ ដើម្បីចែកចាយដល់ពួកគេ។

### *មូលនិធិសម្រាប់សាលាជម្រើសដែលដំណើរការដោយសមាជិកក្នុងសហគមន៍*

ការអភិវឌ្ឍន៏ដ៏សំខាន់មួយរបស់ IBEC នៅត្រីមាសទី២នោះគឺការបណ្តុះបណ្តាលផែនការសាលានៅតាមសាលាពាក់កណ្តាលជុំនៅគ្រប់ខេត្តនៃគម្រោង។ សាលាពាក់កណ្តាលជុំ គឺជាសាលាដែលចូលរួមនៅក្នុងគម្រោង IBEC ហើយមិនបានទទួលការគាំទ្រក្រោមគម្រោងសាលាសដើម្បីជីវិតដែលឧបត្ថម្ភមូលនិធិដោយ USAID ពីមុនមក។ ហេតុនេះហើយទើបសកម្មភាពនេះបានទទួលឧបត្ថម្ភមូលនិធិទ្រង់ទ្រាយតូចៗនៅក្នុងឆ្នាំទីមួយក្នុងលក្ខណៈត្រៀមដើម្បីឈានទៅដល់ការដំណើរការធ្វើផែនការពេញលេញនៅឆ្នាំក្រោយ។ ផ្អែកលើការសម្រេចចិត្តក្នុងការជ្រើសរើសដែលធ្វើឡើងក្នុងត្រីមាសនាពេលកន្លងទៅ នាយកសាលា លោកគ្រូ អ្នកគ្រូ និងសមាជិកសហគមន៍សរុបមានចំនួន ៦៣៨នាក់ មកពីសាលាមធ្យមសិក្សាពាក់កណ្តាលជុំចំនួន ៥៣នាក់ បានបណ្តុះបណ្តាលនូវជំនាញធ្វើផែនការផ្អែកលើគោលដៅ ដែលអាចនាំឱ្យសម្រេចការអភិវឌ្ឍន៏ផែនការកែលម្អសាលារៀន។ ផែនការសាលាទាំងឡាយត្រូវបានអនុម័តដោយក្រុមត្រួតពិនិត្យ ដែលមានមូលដ្ឋាននៅមន្ទីរអប់រំខេត្ត ហើយមូលនិធិត្រូវបានផ្តល់កាលពីខែមិនា។ ជំនួយបន្តិចបន្តួច (៥០០ ដុល្លា ឬតិចជាងនេះ អាស្រ័យលើទំហំនៃសាលា) ។

ដោយផ្អែកទៅលើផែនការសាលាទាំងសាលាពេញជុំ និងសាលាពាក់កណ្តាលជុំ បុគ្គលិក IBEC បានជួយពេញមួយត្រីមាសនូវបច្ចេកទេសសម្រាប់អនុវត្តន៏ការងារផ្សេងៗដូចជាបណ្តុះបណ្តាលបុគ្គលិកចំនួន ១៦៨ រូប មកពី ៨៧ សាលា ដើម្បីបង្កើត និងពង្រឹងក្រុមប្រឹក្សាកុមារ និងបណ្តុះបណ្តាលបណ្ណារក្សចំនួន ៩៥ រូប ។ IBECក៏បានជួយជ្រោមជ្រែងបង្កើតបណ្តាញកុមារជួយកុមារផងដែរ។ មកដល់ពេលនេះបានឱ្យដឹងថា បានផ្តល់សេវាកម្មផ្សេងៗជួយដល់កុមារចំនួន ៤ ៧៨៤ នាក់ហើយក្នុងត្រីមាសនេះ។ ចំពោះគម្រោងកែលម្អហេដ្ឋារចនា សម្ព័ន្ធនិងប្រព័ន្ធទឹកស្អាត សកម្មភាពការងារចំនួន ៧១០ កំពុងដំណើរការយ៉ាងរលូននៅទូទាំងគ្រប់ខេត្តនៃគម្រោង។ ការត្រួតពិនិត្យឡើងវិញអំពីផលប៉ះពាល់លើ បរិស្ថានត្រូវបានបញ្ចប់ និងត្រូវបាន USAID យល់ព្រមអនុម័តកាលពីខែកុម្ភៈ ឆ្នាំ២០១០ កន្លងទៅថ្មីៗនេះ។ IBECក៏បានកសាងថ្នាក់រៀនកម្រិតមធ្យមសិក្សាចំនួន៨ថែមទៀតនៅក្នុងសហគមន៏ដាច់ស្រយាលផងដែរ ។ រយៈពេលតែពីរត្រីមាសប៉ុណ្ណោះ កុមារចំនួន ៤៧៦ នាក់ ដែលមិនមានឱកាសបានទទួលការអប់រំពីមុនមក ឥឡូវនេះ កំពុងតែបានចូលរៀននៅសាលាទាំងនេះ ។

## ការសម្រេចបានជោគជ័យ

ស្វាយលើគឺជាភូមិដាច់ស្រយាលមួយ នៅក្នុងប្រទេសកម្ពុជា ដែលមានចម្ងាយប្រមាណ ៣៥ គីឡូម៉ែត្រ ពីទីរួមស្រុកស្នួល ក្នុងស្រុកស្នួលនៃខេត្តក្រចេះ។ នៅក្នុងភូមិនេះ មានប្រជាជនប្រមាណជា ១១៥ គ្រួសារតែប៉ុណ្ណោះ។ តាមរយៈការផ្តល់ស្ថិតិពីប្រធានភូមិ បានឱ្យដឹងថានៅក្នុងភូមិនេះមានកុមារ ដែលមិនបានចូលរៀនចំនួនពី ៨០ ទៅ ១០០ នាក់ ដែលមាន អាយុពី ៨ ទៅ ១៥ ឆ្នាំ។

ក្រោមគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) សាលាឆ្លងកាត់(ICR) ត្រូវបានបង្កើតឡើង ដែលមានឈ្មោះថា "**សាមគ្គី**"។ ICR បានទទួលមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៏អន្តរជាតិ (USAID)។ ការងារនេះដំណើរការទៅបានក៏ដោយសារតែមានកិច្ចសហការគាំទ្រពីសហគមន៏ ដូចជាក្រោមរូបភាពជួយជាកំលាំងពលកម្ម និងសំភារៈផ្សេងៗផងដែរ។ លោក កែវ ហេង ដែលជាប្រធានភូមិបានបញ្ជាក់អោយដឹងផងដែរថា ប្រជាជននៅក្នុងសហគមន៏តែងតែស្រមៃសង្ឃឹមថា នឹងមានសាលារៀននៅជិតភូមិរបស់ពួកគាត់ ដើម្បីឱ្យកូនចៅគាត់បានរៀនសូត្រ ប៉ុន្តែជាយូរណាស់មកហើយអ្វីនោះនៅតែជាការស្រមៃដដែល ។ ក្រោមការគាំទ្រពីទីប្រឹក្សាឃុំស្វាយជ្រៀស ភូមិនេះបានធ្វើការទាក់ទងជាមួយនិងគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) អំពីការបង្កើត ICR សំរាប់សហគមន៏នេះ ដែលនៅក្នុងភូមិនេះមានអ្នកមិនចេះអក្សរប្រហែលជា ៩០ % ។ លោកហេងបានបញ្ជាក់បន្ថែមទៀតថាដោយមានការជួយឧបត្ថម្ភពី IBEC ការជ្រើសរើសគ្រូបង្រៀនក្នុងសហគមន៏ត្រូវបានមានដំណើរការឡើង ហើយបច្ចុប្បន្ននេះមានកុមារ ៧០ នាក់ ហើយដែលបានចូលរៀននៅសាលាថ្មីនេះ។

លោក កង សាម៉េត ប្រធានកំរងសាលាជ្រៀសបាននិយាយផងដែរថា ប្រជាជននៅក្នុងសហគមន៏នេះមានចិត្តសប្បាយ រីករាយជាខ្លាំង ក្រោមការជួយឧបត្ថម្ភពីគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាហៅកាត់ថា (IBEC) ដោយសារតែគម្រោងនេះ ទើមមានការរីកដុះដាលលើកម្មវិធីអប់រំនេះទៅមុខយ៉ាងរលូន។ ប្រជាជនទាំងពួងក៏សង្ឃឹមដែរថា IBEC នឹងជួយឱ្យមានសេវាខាងផ្នែកអប់រំនេះឱ្យរិតតែរីកចំរើនទៅមុខនាពេលអនាគតទៀតផង។



## សមាសភាគ ៣ : កែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

គោលការណ៍សំខាន់ៗរបស់IBEC ផ្តោតលើសកម្មភាពបំប៉នគ្រូ ការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍ ។ នៅក្នុងត្រីមាសទី២នេះ គឺចំបាច់ត្រូវមានការវាយតម្លៃចំពោះគណៈកម្មការទ្រទ្រង់សាលារៀន ដែលត្រូវធ្វើឡើងនៅតាមសាលាគោលដៅ ដោយស្របជាមួយនិងសកម្មភាពបណ្តុះបណ្តាលសមត្ថភាពផងដែរ ។ សិក្ខាសាលាមួយស្តីពីគណៈកម្មការទ្រទ្រង់សាលារៀនត្រូវបានធ្វើឡើង ដោយមានសិក្ខាកាមចំនួន ៣៨៤ នាក់ ដែលមកពីសាលាចំនួន ១៥៦ និងប្រធានបទដែលត្រូវលើកយកមកពិភាក្សា មានដូចជា គោលនយោបាយសាលាកុមារមេត្រីត្រូវយកមកអនុវត្តជាក់ស្តែងបែបណានៅតាមសាលារៀនលើតួនាទី ភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលារៀនក្នុងការងារកែលម្អសាលារៀន និងផែនការអនុវត្តរបស់សហគមន៍នាពេលអនាគត (ផ្តែកលើចំនុចខ្លាំង និងចំនុចខ្សោយដែលកំពុងធ្វើ) សិក្ខាសាលាស្តីពីការបំប៉នគ្រូ និងគ្រប់គ្រងសាលារៀនក៏បានរៀបចំធ្វើឡើងនៅក្នុងត្រីមាសនេះផងដែរ ដោយផ្តោតសំខាន់ទៅលើផែនការកែលម្អសាលារៀន (សាលាពាក់កណ្តាលជុំនៃគម្រោង IBEC) និងផែនការចីរភាព ។ លើសពីនេះទៀតគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានជួយកំណត់ជ្រើសរើសសមាជិកបណ្តាញក្រុមគាំទ្របច្ចេកទេសនៅតាមសាលាមធ្យមសិក្សាពេញជុំ ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលស្តីពីតួនាទីភារកិច្ចនៅតាមសាលារៀន និងតើត្រូវធ្វើការអង្កេតតាមដានលើការបង្រៀនបែបណា ។ការប្រើប្រាស់បណ្តាញសមាជិកក្រុមគាំទ្របច្ចេកទេស គឺក្នុងគោលបំណងកសាងសកម្មភាពនៃការបង្រៀនរបស់គ្រូឱ្យមានចីរភាព ដោយបង្កើតនូវក្រុមជួយគ្នាទៅវិញទៅមកនៅតាមសាលាគោលដៅ ។ បុគ្គលិករបស់ IBEC ក៏បានរៀបចំដំណើរទស្សនកិច្ចគ្នាទៅវិញទៅមកលើសាលាបង្ហាញផ្លូវមួយចំនួន ដើម្បីបង្ហាញពីការអភិវឌ្ឍន៍ជាក់ស្តែង ។ ក្នុងកម្មសិក្សាបែបទស្សនកិច្ចគ្នាទៅវិញទៅមកក្នុងត្រីមាសនេះ ជាសរុបមានអ្នកចូលរួមចំនួន ៦៧៨ ហើយ ។



## សមាសភាគ ៤ : បង្កើនបរិបទពាក់ព័ន្ធលើការអប់រំ

នៅក្នុងសមាសភាគទី៤នេះ IBEC ផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍បំណិនជីវិត ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្កើនឱកាសប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មានវិទ្យា ។ សិក្ខាសាលាពិនិត្យឡើងវិញមួយដែលមានការចូលរួមពីខាងក្រសួង និងសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិជាចុងក្រោយមួយដែលត្រូវបានគេគ្រោងនឹងរៀបចំនៅក្នុងរដូវក្តៅនៃឆ្នាំ២០១០នេះ ជាចំនុចសម្គាល់នៃការចាប់ផ្តើមជាផ្លូវការនៃការសាកល្បងអនុវត្តគម្រោងបំណិនជីវិតរបស់ IBEC ។

វគ្គបណ្តុះបណ្តាលទាក់ទងនិងការអប់រំពីបំណិនជីវិតត្រូវបានរៀបចំឡើងនៅក្នុងត្រីមាសកន្លងទៅសម្រាប់ផ្តល់ដល់គ្រូបង្រៀនទាំងនៅសាលាបឋមសិក្សា និងមធ្យមសិក្សា ។ វគ្គបណ្តុះបណ្តាលនេះរួមបញ្ចូលវិស័យផ្សេងៗជាច្រើន ដែលទាក់ទងនិងបំណិនជីវិត ។ សកម្មភាពបណ្តុះបណ្តាលបំណិនជីវិត ចំនួន ២៩២ ត្រូវបានធ្វើឡើងនៅក្នុងវិស័យទាំងអស់នេះ ដោយមានសិស្សចំនួន ១៤ ០៨៧ នាក់ហើយបានចូលរួម ។

សកម្មភាពបណ្តុះបណ្តាលគ្រូបង្រៀនជាច្រើនក៏ត្រូវបានរៀបចំធ្វើក្នុងត្រីមាសនេះដែរ ជាពិសេស គឺការគាំទ្រដល់វគ្គបណ្តុះបណ្តាលសាលាកុមារមេត្រីសម្រាប់គ្រូបង្រៀនថ្មីៗ ។ គ្រូបង្រៀនមកពីសាលាមធ្យមសិក្សាចំនួន ១១៣ រូបបានទទួលការបណ្តុះបណ្តាលនៅក្នុងត្រីមាសនេះ ។ វគ្គបណ្តុះបណ្តាលបន្ថែមទៀតគ្រោងនឹងរៀបចំធ្វើក្នុងខេត្តសៀមរាបក្នុងត្រីមាសបន្ទាប់ ។ ក្រុមជំនួយបច្ចេកទេសក៏នឹងត្រូវបានបង្កើតឡើងនៅសាលាកម្រិតមធ្យមសិក្សាទៀតដោយចាប់ផ្តើមពីត្រីមាសក្រោយនេះទៅ ។ IBEC បានធ្វើឱ្យមានការរីកចម្រើនជាច្រើននៅក្នុងការបង្កើនឱកាស



ប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មានវិទ្យាក្នុងត្រីមាសនេះបានបង្កើតបន្ទប់កុំព្យូទ័រថ្មីទៀតចំនួន៦ បន្ថែមទៅលើបន្ទប់កុំព្យូទ័រចំនួន១១ ដែលត្រូវបានបង្កើតឡើងតាំងពីមុនមក ។ កម្មវិធីសាលារៀនដើម្បីជីវិត ។ IBEC កំពុងតែប្រើប្រាស់បច្ចេកវិជ្ជាថាមពលពន្លឺព្រះអាទិត្យ ដើម្បីធានាថាបន្ទប់កុំព្យូទ័រដែលត្រូវបានផ្តល់ឱ្យទាំងឡាយសុទ្ធតែត្រូវការការថែរក្សាតិច ប្រើប្រាស់ថាមពលតិច និងដើម្បីធានាដល់ការសន្សំសំចៃចំពោះរាល់ការចំណាយទូទៅ ។ ការរីកចម្រើននាពេលថ្មីៗនេះ បាននាំឱ្យមានការប្រើប្រាស់កុំព្យូទ័រប្រភេទថាមពលពន្លឺព្រះអាទិត្យ ដែលមានទំហំតូចជាង ដែលគេប្រើប្រាស់ពីមុនមកដល់ទៅ១០ដង និងថោកជាង២០ដុល្លាក្នុងមួយសំណុំ ។ ការសន្សំសំចៃទាំងនេះបានធ្វើឱ្យ IBEC មានលទ្ធភាពបង្កើនចំនួនកុំព្យូទ័រនៅក្នុងបន្ទប់កុំព្យូទ័រនីមួយៗ ពី១១គ្រឿងទៅដល់ ១៣ គ្រឿង ដែលជាការកើនឡើងក្នុងអត្រា២០% និងចំណាយប្រាក់កាន់តែតិច ។ ក្នុងត្រីមាសនេះ IBEC បានផ្តោតការយកចិត្តទុកដាក់មិនមែនត្រឹមតែទៅលើការបង្កើតបន្ទប់កុំព្យូទ័រប៉ុណ្ណោះទេ តែមានការបណ្តុះបណ្តាលគ្រូចំនួន៤៥រូប ដើម្បីជួយដល់ការប្រើប្រាស់សម្ភារៈបច្ចេកវិជ្ជាព័ត៌មានវិទ្យា និងបណ្តុះបណ្តាលគ្រូជំនាញផ្នែកកុំព្យូទ័រចំនួន២៨រូបផ្សេងទៀតផងដែរ ។